**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**
គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩
ក្នុងក្របខណ្ឌទូទាំងប្រទេស(គ.វ.ក-១៩)

លេខ ៩៨៤/២១ គ.វ.ក-១៩

ថ្ងៃ ១រោច ............ខែភទ្របទ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០២១

# សេចក្តីជូនព័ត៌មាន
## ស្តីពី
## ការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ជូនដល់ប្រជាពលរដ្ឋ ក្រោយពីបានព្យាបាលជាសះស្បើយពីជំងឺកូវីដ-១៩ រយៈពេលចាប់ពី៤ខែឡើង

គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩) សូមជម្រាបជូនដល់សាធារណជនជ្រាបថា យោងតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី** ក្នុងការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនដល់អ្នកដែលបានព្យាបាលជាសះស្បើយពីជំងឺកូវីដ-១៩ ព្រមទាំងយោងតាមអនុសាសន៍របស់អង្គការសុខភាពពិភពលោក (World Health Organization) ដែលបានណែនាំឱ្យប្រជាពលរដ្ឋដែលបានព្យាបាលជាសះស្បើយពីជំងឺកូវីដ-១៩ អាចមកទទួលការចាក់វ៉ាក់សាំងកូវីដ-១៩ ដើម្បីបង្កើនភាពស៊ាំទប់ទល់នឹងវីរុសកូវីដ-១៩ ដូចនេះ គ.វ.ក-១៩ សូមគោរពអញ្ជើញប្រជាពលរដ្ឋទាំងអស់ដែលមានអាយុចាប់ពី៦ឆ្នាំឡើង ដែលបានព្យាបាលជាសះស្បើយពីជំងឺកូវីដ-១៩ ចាប់ពី៤ខែឡើង ហើយមិនទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ សូមទៅចាក់វ៉ាក់សាំងកូវីដ-១៩ ដោយស្ម័គ្រចិត្ត នៅតាមទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ដូចខាងក្រោម៖

- ចំពោះមន្ត្រីរាជការថ្នាក់ជាតិដែលបានព្យាបាលជាសះស្បើយពីជំងឺកូវីដ-១៩ ចាប់ពី៤ខែឡើង ហើយមិនទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ សូមអញ្ជើញទៅចាក់វ៉ាក់សាំងកូវីដ-១៩ នៅមន្ទីរពេទ្យកាល់ម៉ែត មន្ទីរពេទ្យព្រះអង្គឌួង មន្ទីរពេទ្យកុមារជាតិ មន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត និងមជ្ឈមណ្ឌលជាតិគាំពារមាតា និងទារក។
- ចំពោះមន្ត្រីរាជការថ្នាក់ក្រោមជាតិ និងប្រជាពលរដ្ឋទូទៅ ដែលស្ថិតនៅក្រោមឱវាទរដ្ឋបាលរាជធានី-ខេត្ត ដែលបានព្យាបាលជាសះស្បើយពីជំងឺកូវីដ-១៩ ចាប់ពី៤ខែឡើង ហើយមិនទាន់បានចាក់វ៉ាក់សាំងកូវីដ-១៩ សូមអញ្ជើញទៅចាក់វ៉ាក់សាំងកូវីដ-១៩ នៅតាមមន្ទីរពេទ្យបង្អែករាជធានី-ខេត្ត និងនៅតាមបណ្តាទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ មួយចំនួនទៀតដែលរដ្ឋបាលរាជធានី-ខេត្ត កំពុងបើកដំណើរការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនប្រជាពលរដ្ឋដែលនៅសេសសល់។

ទន្ទឹមជាមួយគ្នានេះដែរ គ.វ.ក-១៩ សូមជម្រាបជូនដល់ ឯកឧត្តម លោកជំទាវ ប្រធានអនុគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌរាជធានី-ខេត្ត សូមណែនាំបន្ថែមដល់ ឯកឧត្តម លោកជំទាវ ប្រធានមន្ទីរសុខាភិបាលរាជធានី-ខេត្ត ណែនាំទៅគ្រប់ទីតាំងចាក់វ៉ាក់សាំងកូវីដ-១៩ ទាំងអស់ឱ្យផ្តល់ការចាក់វ៉ាក់សាំងកូវីដ-១៩ ជូនដល់ក្រុមគោលដៅដែលបានជម្រាបជូនខាងលើឱ្យមានភាពរលូន។



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ៨០ វិថីសម្តេច ប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ (៨៥៥-២៣) ៨៨៥ ៩៧០/៨៨៤ ៩០៩

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ និងស្របពេលជាមួយបរិបទបច្ចុប្បន្ននេះ ដែលកំពុងមានការរាតត្បាតនៅលើពិភពលោក ក៏ដូចជានៅតាមបណ្តាប្រទេសនីមួយៗពីវីរុសកូវីដ-១៩ បំប្លែងខ្លួនថ្មីៗ ជាពិសេសវីរុសបំប្លែងខ្លួនថ្មីប្រភេទដែលតា ដែលកំពុងចរាចរយ៉ាងសកម្មនៅប្រទេសជាច្រើន ក៏ដូចជាប្រទេសកម្ពុជាផងដែរនោះ គ.វ.ក-១៩ សូមអំពាវនាវដល់លោកអ៊ុំ ពូ មីង ពុក ម៉ែ បងប្អូន ព្រមទាំងក្មួយៗ ដែលមានអាយុចាប់ពី៦ឆ្នាំឡើង ក្រោយពីបានព្យាបាលជាសះស្បើយពីជំងឺកូវីដ-១៩ ចាប់ពី ៤ខែឡើង សូមរួសរាន់ស្ម័គ្រចិត្តទៅចាក់វ៉ាក់សាំងកូវីដ-១៩ ឱ្យបានគ្រប់គ្នា ដើម្បីបង្កើតភាពស៊ាំក្នុងសរីរាង្គរបស់ខ្លួន និងភាពស៊ាំក្នុងសហគមន៍ សម្រាប់ទប់ទល់ពីការវាយលុកនៃវីរុសកូវីដ-១៩ កាត់បន្ថយភាពធ្ងន់ធ្ងរនៃអ្នកជំងឺកូវីដ-១៩ កាត់បន្ថយនូវអត្រាសម្រាកពេទ្យ ក៏ដូចជាកាត់បន្ថយជាអតិបរមានូវអត្រាស្លាប់ដែលបណ្តាលមកពីជំងឺកូវីដ-១៩។

ប្រសិនបើបងប្អូនប្រជាពលរដ្ឋមានចម្ងល់ពាក់ព័ន្ធទៅនឹងការចាក់វ៉ាក់សាំងកូវីដ-១៩ សូមទំនាក់ទំនងមកកាន់លេខទូរស័ព្ទខាងក្រោម៖

ក-ក្រុមការងារទំនាក់ទំនងសាធារណៈ /លេខាធិការដ្ឋាន៖

| | | |
|---|---|---|
| ០១២ ៩៨៩ ០៨៥ | ០៨៩ ៩៨០ ៦៦៦ | ០១០ ២៣៣ ៥៨៨ |

ខ-ក្រុមការងារចុះឈ្មោះ និងប្រព័ន្ធព័ត៌មានវិទ្យា៖

| | | |
|---|---|---|
| ០១២ ៨៩៧ ០៨៣ | ០៦៨ ៩០៦ ៦៦៦ | ០១២ ៨៦៨ ៦៤០ |

គ-ក្រុមការងារសុវត្ថិភាពវ៉ាក់សាំង និងប្រាស្រ័យទាក់ទងហានិភ័យ៖

| | | |
|---|---|---|
| ០១២ ៨៨៧ ៣៨៧ | ០១២ ៨៣៦ ៨៦៨ | ០១២ ៨៩១ ៥២៧ |

**រដ្ឋលេខាធិការ និងជាប្រធានគណៈកម្មការចំពោះកិច្ច**
**ចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.ច.ក-១៩)**

វេជ្ជ. ឱ វណ្ណឌីន